N.17
08.5.02

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-៣-២០០២ -ព្រះរាជក្រឹត្យនស/រកត/០៣០២/០៦៨ស្តីពីការតែងតាំងនិងផ្លាស់ប្តូរព្រះរាជអាជ្ញាអមតុលាការ-ចៅក្រម-ប្រធានតុលាការ ១០៦១

២៥-៤-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៤០២/១០៥ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រីជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក **នុប ចន** ១០៦២

២៥-៤-២០០២ -ព្រះរាជក្រឹត្យនស/រកត/០៤០២/១០៦ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រីជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរសេនីយ៍ឯក **កែវ គឹមឈាង** ១០៦៣

២៦ ៤ ២០០២ -ព្រះរាជក្រឹត្យនស/រកព/០៤០២/១០៨ ស្តីពីការតែងតាំងលោកជំទាវ **ឡោក ខេន** ជា **ឧកញ៉ា** ១០៦៤

០៦-៥-២០០២ -ព្រះរាជក្រឹត្យនស/រកត/០៥០២/១១២ស្តីពីការប្រើប្រាស់និងការការពារបដិរូបកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ១០៦៥

០៦-៥-២០០២ -ព្រះរាជក្រឹត្យនស/រកត/០៥០២/១១៣ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា ១០៧១

០៦-៥-២០០២ -ព្រះរាជក្រឹត្យនស/រកត/០៥០២/១១៤ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ១០៧៧


## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


០៣-៥-២០០២ - អនុក្រឹត្យលេខ ៣៨ អនក្រ.បក ស្តីពីការបង្កើតវិទ្យាស្ថានគ្រប់គ្រង និងពត៌មានវិទ្យា ១០៨០

០២-៥-២០០២ - អនុក្រឹត្យលេខ ៣៩ អនក្រ.បក ស្តីពីការបង្វែការគ្រប់គ្រងឥណទានថវិកា ១០៨៣

០២-៥-២០០២ - អនុក្រឹត្យលេខ ២១២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១០៨៥

០២-៥-២០០២ - អនុក្រឹត្យលេខ ២១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៨៦

០២-៥-២០០២ អនុក្រឹត្យលេខ ២១៤ អនក្រ.តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ១០៨៧

០២-៥-២០០២ អនុក្រឹត្យលេខ២១៥អនក្រ.តតស្តីពីការតែងតាំងនិងផ្លាស់ប្តូរមុខងារនាយទាហាន ១០៨៩

០២-៥-២០០២ - អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហាន ១០៩១
០៣-៥-២០០២ - អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០៩៣
០៣-៥-២០០២ - អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៩៦
០៣-៥-២០០២ - អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៩៧
០៣-៥-២០០២ - អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១០៩៨
០៣-៥-២០០២ - អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១០៩៩
០៨-៥-២០០២ - អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១០០
០៨-៥-២០០២ - អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១១០២
០៨-៥-២០០២ - អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១១០៣

## ២_សេចក្តីសំរេច

០៨-៥-២០០២ - សេចក្តីសំរេចលេខ ២៦ សសរ ស្តីពីការតែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១១០៤
08-5-2002 - Decision N0 26 DC Appointment of and Advisor to the Prime Minister of the Kingdom of Cambodia ១១០៥
០៨-៥-២០០២ - សេចក្តីសំរេចលេខ ២៧ សសរ ស្តីពីការលុបកិច្ចព្រមព្រៀងវិនិយោគ អាជ្ញាប័ណ្ណ ធ្វើអាជីវកម្មនិងកិច្ចសន្យាធ្វើអាជីវកម្មព្រៃសម្បទានរបស់ក្រុមហ៊ុនចំនួន០២ ១១០៦
០៨-៥-២០០២ - សេចក្តីសំរេចលេខ ២៨ សសរ ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រីស្តីទី ១១០៨

# III- ការងារបណ្តាក្រសួង

## ១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-៥-២០០២ -ប្រកាសលេខ ៣៣៤ សហវ.ប្រក ស្តីពីការបង្កើតនិងតែងតាំងមន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សា មូលនិធិឃុំ-សង្កាត់ ១១០៩
០៣-៥-២០០២ -ប្រកាសលេខ ៣៣៥ សហវ .ប្រក ស្តីពីការបង្កើតគណៈកម្មការដឹកនាំគំរោងស្រោចស្រព ស្ទឹងជីនិតនិងហេដ្ឋារចនាសម្ព័ន្ធជនបទ ១១១១

## ២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៧-៥-២០០២ -ប្រកាសលេខ១៣១ Moc/M2002 ស្តីពីការកែសំរួលនិងបំពេញបន្ថែមប្រកាសលេខ ៣៩៧ Moc/M2001 បង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការកូដិចជាតិ ១១១៤

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៦៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០២

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង :

១- លោក **លូ ស៊ូសម្បត្តិ** ព្រះរាជអាជ្ញារងអមតុលាការខេត្តមណ្ឌលគិរី ជាប្រធានតុលាការខេត្តមណ្ឌលគិរី

២- លោក **អាំង មាលតី** ចៅក្រមតុលាការខេត្តសៀមរាប ជាអនុប្រធានតុលាការខេត្តសៀមរាប ។

**មាត្រា ២ :** ត្រូវបានផ្ទេរភារកិច្ច :

១- លោក ថៅ សារិន ប្រធានតុលាការខេត្តព្រៃវែង អោយទៅបំរើការងារ ជាអនុប្រធានតុលាការខេត្តស្វាយរៀង ដោយរក្សាទុកកាំប្រាក់បៀវត្សដដែល ។

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០២*

*ពរល-០២-០៣-០០៧៤*

លេខ: ១០២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី ឆាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០២

## ត្រាស់បង្គាប់

មាត្រា១ .- ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសពលោកវរៈសេនីយ៍ឯក **គុច ចង** អត្តលេខ ០៣៤៦ អនុប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងមហាផ្ទៃ ។

មាត្រា២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

៣រល.០៤០៤-០០១១៥

លេខ: ១០៣ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាលី ប៊ាន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០២

## ត្រាស់បង្គាប់

មាត្រា១ .- ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនចំពោះសពលោកវរៈសេនីយ៍ឯក **កែវ គឹមឈាង** អត្តលេខ០១៨៥ អនុប្រធាននាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងមហាផ្ទៃ ។

មាត្រា២ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣កស.០៤០៤.០០១១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២

លេខ: ១០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ឆាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១០៩

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកជំទាវ ឡោក ខេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ១០៥ស.ល

ដើម្បីចម្លងចែក

៣រស.០២០៤.០០១១៩

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១១៥

## ស្តីពី

## ការប្រើប្រាស់ និងការការពារបដិរូបកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៥៨ ស្តីពីការទទួលស្គាល់សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានទ្រង់យល់មាត្រា ២៦ នៃអនុសញ្ញាទីក្រុងហ្សឺណែវលើកទី ១ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ និងក្នុងកាតព្វកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងពិធីសារបន្ថែម ចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៩៧៧ រួមទាំងឧបសម្ព័ន្ធទី ១ នៃពិធីសារបន្ថែមទី ១ ដែលជាបទបញ្ជាស្តីពី ការសំគាល់អង្គភាព និងមធ្យោបាយដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រ
- បានទ្រង់យល់បទប្បញ្ញត្តិស្តីពី ការប្រើប្រាស់បដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ដោយសមាគមជាតិ ដែលបានត្រូវអនុម័ត ដោយសន្និសីទអន្តរជាតិលើកទី ២០ នាឆ្នាំ ១៩៨២ របស់កាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ហើយនិងការកែប្រែបន្តបន្ទាប់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាសម្គាល់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ កំណត់ការប្រើប្រាស់ និងការការពារបដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម លើផ្ទាំងសំពត់ស រូបភាពកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម និងសញ្ញាសំរាប់សំគាល់អង្គភាពនិងមធ្យោបាយដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្នុងពេលមានជំលោះប្រដាប់អាវុធ បដិរូបដែលប្រើប្រាស់ជាឧបករណ៍សំរាប់ការពារ គឺជាសញ្ញាដែលគេមើលឃើញថាជាសញ្ញាការពារ ដូចដែលអនុសញ្ញាទីក្រុងហ្សឺណែវ និងពិធីសារបន្ថែមទាំងឡាយរបស់អនុសញ្ញាបានអនុញ្ញាតឱ្យបុគ្គលិកពេទ្យ ព្រមទាំងអង្គភាពនិងរថយន្តពេទ្យប្រើប្រាស់ ។ បដិរូបនេះ ត្រូវមានទំហំធំសមស្រប ។

បដិរូបដែលប្រើជាឧបករណ៍សំរាប់សំគាល់ បង្ហាញឱ្យដឹងថា មនុស្សឬវត្ថុមួយនោះ មានទំនាក់ទំនងទៅនឹងស្ថាប័នកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ។ ទំហំរបស់បដិរូបនេះ ត្រូវតូចល្មមសមស្រប ។

## ជំពូកទី ២

## ការប្រើប្រាស់បដិរូបសំរាប់ការពារ

**មាត្រា ៣.-**

ការប្រើប្រាស់ដោយសេវាវេជ្ជសាស្ត្ររបស់កងកម្លាំងប្រដាប់អាវុធ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងការពារជាតិ សេវាកម្មវេជ្ជសាស្ត្ររបស់កងយោធពលខេមរភូមិន្ទ ត្រូវប្រើ បដិរូបកាកបាទក្រហម ដើម្បីកំណត់សំគាល់បុគ្គលិក អង្គភាព និងមធ្យោបាយដឹកជញ្ជូនរបស់ពេទ្យ តាមជើងគោក ជើងទឹក និងលើអាកាស ទាំងនៅពេលមានសន្តិភាព និងពេលមានជំលោះប្រដាប់អាវុធ ។

បុគ្គលិកពេទ្យកងយោធពលខេមរភូមិន្ទ ត្រូវពាក់ក្រណាត់ប៉ាន់ដៃនិងត្រូវមានអត្តសញ្ញាណប័ណ្ណសំគាល់ខ្លួន ដែលមានបដិរូបនៅលើនោះ ។ ក្រណាត់ប៉ាន់ដៃ និងអត្តសញ្ញាណប័ណ្ណទាំងនោះ ត្រូវផ្តល់ឱ្យដោយក្រសួងការពារជាតិ ។ បុគ្គលិកសាសនាដែលធ្វើការជាមួយកងទ័ព ត្រូវបានទទួលការការពារដូចជាបុគ្គលិកពេទ្យដែរ ហើយត្រូវមានសញ្ញាសំគាល់តាមរបៀបដូចគ្នានេះដែរ ។

**មាត្រា ៤.-**

ដោយមានការអនុញ្ញាតទាន់ពេលវេលា និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងសុខាភិបាល

នៅពេលមានជំលោះប្រដាប់អាវុធ បុគ្គលិកពេទ្យស៊ីវិល មន្ទីរពេទ្យនិងអង្គភាពពេទ្យស៊ីវិល ក៏ដូចជាយានជំនិះពេទ្យស៊ីវិលដែលបានទទួលការចាត់តាំងឱ្យដឹកជញ្ជូន និងព្យាបាលអ្នករបួស អ្នកជម្ងឺ និងអ្នកលង់ទឹកដោយសារកប៉ាល់លិច ត្រូវប្រើប្រាស់បដិរូបដែលប្រើជាឧបករណ៍ការពារ ។

បុគ្គលិកពេទ្យស៊ីវិល ត្រូវពាក់ក្រណាត់ប៉ាន់ដៃ និងត្រូវកាន់អត្តសញ្ញាណប័ណ្ណដែលមានបដិរូប ។ ក្រណាត់ប៉ាន់ដៃ និងអត្តសញ្ញាណប័ណ្ណទាំងនេះ ត្រូវផ្តល់ឱ្យដោយក្រសួងសុខាភិបាល ។

បុគ្គលិកស៊ីវិលខាងសាសនា ដែលធ្វើការអមជាមួយមន្ទីរពេទ្យ ហើយនិងអង្គភាពពេទ្យដទៃទៀត ត្រូវមានសញ្ញាសំគាល់តាមរបៀបដូចគ្នានេះដែរ ។

**មាត្រា ៥ .—**

កាកបាទក្រហមកម្ពុជា ត្រូវបានអនុញ្ញាតឱ្យដាក់បុគ្គលិកពេទ្យ មន្ទីរពេទ្យ និងមធ្យោបាយដឹកជញ្ជូនទៅតាមតម្រូវការប្រើប្រាស់នៃសេវាកម្មវេជ្ជសាស្ត្ររបស់កងទ័ព ។ បុគ្គលិកពេទ្យ មន្ទីរពេទ្យ និងមធ្យោបាយដឹកជញ្ជូនទាំងនោះ ត្រូវអនុវត្តច្បាប់និងបទបញ្ជាយោធា និងត្រូវបានទទួលការអនុញ្ញាតពីក្រសួងការពារជាតិឱ្យបំពាក់បដិរូបរបស់កាកបាទក្រហម ជាឧបករណ៍សំរាប់ការពារ ។

បុគ្គលិកពេទ្យទាំងនោះ ត្រូវពាក់ក្រណាត់ប៉ាន់ដៃ និងកាន់អត្តសញ្ញាណប័ណ្ណ ដូចមានចែងក្នុងមាត្រា ៣ កថាខ័ណ្ឌទី ២ នៃព្រះរាជក្រឹត្យនេះ ។

កាកបាទក្រហមកម្ពុជា អាចនឹងផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់បដិរូប ជាឧបករណ៍សំរាប់ការពារបុគ្គលិកពេទ្យ និងអង្គភាពពេទ្យរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការប្រើប្រាស់បដិរូបសំរាប់សំគាល់

**មាត្រា ៦ .—**

កាកបាទក្រហមកម្ពុជា បានទទួលការអនុញ្ញាតឱ្យប្រើប្រាស់បដិរូប ជាឧបករណ៍សំរាប់បង្ហាញឱ្យឃើញថា មនុស្ស ឬវត្ថុមួយនោះ មានទំនាក់ទំនងទៅនឹងកាកបាទក្រហមកម្ពុជា ។ បដិរូបប្រើសំគាល់បែបនេះ ត្រូវមានទំហំតូចល្មម ដើម្បីជៀសវាងការភ័ន្តច្រឡំ ដែលអាចកើតឡើងជាមួយនឹងបដិរូបដែលប្រើជាឧបករណ៍សំរាប់ការពារ ។

កាកបាទក្រហមកម្ពុជា ត្រូវអនុវត្តបទបញ្ជានានាស្តីពី ការប្រើប្រាស់បដិរូបរបស់កាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ។

ដោយមានការឯកភាពជាមុនពីកាកបាទក្រហមកម្ពុជា សមាគមជាតិកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហមនៃប្រទេសផ្សេងទៀត ដែលស្ថិតនៅលើទឹកដីនៃប្រទេសកម្ពុជា ត្រូវប្រើបដិរូបតាមល័ក្ខខ័ណ្ឌដូចគ្នានេះដែរ ។

## ជំពូកទី ៤
## ការប្រើប្រាស់បដិរូបដោយអង្គការកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមអន្តរជាតិ

**មាត្រា ៧.–**

គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម និងសហព័ន្ធអន្តរជាតិនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម អាចប្រើប្រាស់បដិរូបបានគ្រប់ពេលវេលា និងក្នុងគ្រប់សកម្មភាពរបស់ខ្លួន ។

## ជំពូកទី ៥
## ការប្រើប្រាស់មិនត្រឹមត្រូវនូវបដិរូប កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម

**មាត្រា ៨.–**

អាជ្ញាធរកម្ពុជា ជានិច្ចកាលត្រូវធានាឱ្យមានការអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវវិធានស្តីពីការគ្រប់គ្រង ការប្រើប្រាស់បដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ការប្រើឈ្មោះ កាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ព្រមទាំងសញ្ញាសំគាល់ទាំងឡាយ ។ អាជ្ញាធរ ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ ការត្រួតពិនិត្យមនុស្សទាំងឡាយដែលបានទទួលការអនុញ្ញាតឱ្យប្រើបដិរូប ឈ្មោះ និងសញ្ញាសំគាល់ ។

អាជ្ញាធរ ត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការនូវការប្រើខុស ជាពិសេសត្រូវធ្វើការផ្សព្វផ្សាយអំពីវិធានដែលបានលើកមកនេះ ឱ្យបានទូលំទូលាយតាមដែលអាចធ្វើបាន ក្នុងចំណោមកងកម្លាំងប្រដាប់អាវុធ កងកម្លាំងនគរបាល អាជ្ញាធរសាធារណៈ និងពលរដ្ឋស៊ីវិល ។

**មាត្រា ៩.–**

កាកបាទក្រហមកម្ពុជា ត្រូវសហការយ៉ាងសកម្មជាមួយនឹងអាជ្ញាធរសមត្ថកិច្ច នៅក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្ការ និងបង្ក្រាបការប្រើខុសណាមួយ ។ កាកបាទក្រហមកម្ពុជា ត្រូវបានផ្តល់សិទ្ធិឱ្យជូនដំណឹងទៅរាជរដ្ឋាភិបាល អំពីការប្រើខុសណាមួយ ព្រមទាំងចូលរួមក្នុងការប្តឹងតាមផ្លូវច្បាប់ ឬតាមផ្នែករដ្ឋបាលដែលពាក់ព័ន្ធ ។

## ជំពូកទី ៦
## ការចុះបញ្ជីឈ្មោះរបស់សមាគមជាតិ ឈ្មោះពាណិជ្ជកម្ម និងនិក្ខិតសញ្ញា

**មាត្រា ១០.–**

ការចុះបញ្ជីឈ្មោះរបស់សមាគមជាតិ-ឈ្មោះពាណិជ្ជកម្មនានា និងការចុះនិក្ខិតសញ្ញា សញ្ញាសំគាល់ផ្នែកពាណិជ្ជកម្ម និងគំរូផ្នែកឧស្សាហកម្ម និងការប្រើប្រាស់ ការគូរបដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ឬការប្រើឈ្មោះថា កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម ត្រូវបានហាមឃាត់ ។

មានតែកាកបាទក្រហមកម្ពុជាតែមួយគត់ ដែលអាចចុះបញ្ជីសុំការប្រើប្រាស់បដិរូបកាកបាទក្រហម បាន ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១១ .-**

ជនណាដែលធ្វើតាមទំនើងចិត្ត ដោយពុំមានការអនុញ្ញាតត្រឹមត្រូវ ពុំមានការផ្តល់សិទ្ធិប្រើប្រាស់បដិរូបកាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ពាក្យ កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម សញ្ញាសំគាល់ ឬសញ្ញាផ្សេងណាមួយ រូបភាព ឬសញ្ញាភ្លែងបន្លំ ឬដែលអាចធ្វើឱ្យមានការភ័ន្តច្រឡំ ដោយមិនគិតទៅដល់គោលបំណងនៃការប្រើនេះ ហើយជាពិសេស ជនណាដែលបានយកបដិរូប ឬយកពាក្យនេះទៅដាក់លើសញ្ញាសំគាល់ផ្សេងៗដូចជា ប័ណ្ណប្រៃសណីយ៍ ប័ណ្ណប្រកាស ក្រដាសផ្សព្វផ្សាយ ឬឯកសារពាណិជ្ជកម្ម ឬបានបិទភ្ជាប់បដិរូប ឬពាក្យទាំងនោះលើទំនិញ ឬលើកញ្ចប់ ឬបានលក់ ឬផ្តល់ឱ្យសំរាប់ដាក់លក់ ឬដាក់ក្នុងចរាចរទំនិញ នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ។

ប្រសិនបើការរំលោភបំពាននេះ បានធ្វើឡើងដោយការដឹកនាំរបស់អង្គភាពសហគ្រាស ក្រុមហ៊ុន/ សមាគមណាមួយ ការផ្តន្ទាទោស នឹងត្រូវអនុវត្តទៅលើបុគ្គលណាដែលបានធ្វើការរំលោភបំពាននេះ ឬទៅលើបុគ្គលណាដែលបានបញ្ជាឱ្យមានការរំលោភបំពាននេះ ។

**មាត្រា ១២ .-**

ជនណាដែលគ្មានការអនុញ្ញាតត្រឹមត្រូវ បានធ្វើតាមទំនើងចិត្ត ឬបានចេញបញ្ជាឱ្យធ្វើរហូតដល់បណ្តាលឱ្យស្លាប់ ឬបណ្តាលឱ្យមានរបួសជាទម្ងន់ទៅលើខ្លួនប្រាណ ឬប៉ះពាល់សុខភាពរបស់គូសត្រូវ ដោយប្រើប្រាស់ដោយទុច្ចរិតនូវបដិរូបរបស់កាកបាទក្រហម ឬអឌ្ឍច័ន្ទក្រហម ឬសញ្ញាសំគាល់ គឺជាការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ។ ការប្រព្រឹត្ត បែបនេះ នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន ។

ការប្រើប្រាស់ដោយទុច្ចរិតមានន័យថា មានគោលបំណងបោកប្រាស់គូសត្រូវ ឬដែលនាំឱ្យបុគ្គលនោះជឿជាក់ថា ជនទុច្ចរិតនេះបានទទួលសិទ្ធិក្នុងការទទួល ឬមានកាតព្វកិច្ចការពារ ដែលវិធានទាំងឡាយរបស់ច្បាប់មនុស្សធម៌អន្តរជាតិ បានផ្តល់ឱ្យ ។

**មាត្រា ១៣ .-**

ដោយហេតុថា ការភាន់ច្រឡំអាចនឹងកើតមានឡើងរវាងបដិរូបរបស់ប្រទេសស្វីស និងបដិរូបកាកបាទក្រហម ការប្រើប្រាស់សញ្ញាកាកបាទពណ៌សនៅលើផ្ទៃពណ៌ក្រហម ឬសញ្ញាណាដែលធ្វើប្រដូច ទោះបីជានិក្ខិតសញ្ញា ឬសញ្ញាពាណិជ្ជកម្ម ឬជាសមាសភាគមួយនៃសញ្ញាទាំងនេះ ឬក្នុងគោលបំណងប្រឆាំងនឹងពាណិជ្ជកម្ម

ស្មើភាព ឬក្នុងស្ថានភាពសំដៅធ្វើឱ្យប៉ះពាល់ដល់មនោសញ្ចេតនាជាតិរបស់ស្ទីស ត្រូវបានហាមឃាត់ ហើយអ្នកដែលបានប្រព្រឹត្តបទល្មើស នឹងត្រូវផ្ដន្ទាទោសទៅតាមច្បាប់ជាធរមាន ។

**មាត្រា ១៤ .—**

ការរឹបអូសយកវត្ថុ និងសំភារៈនានាដែលត្រូវបានប្រើប្រាស់ ការដកឬលុបចោលបដិរូបរបស់កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម និងពាក្យ កាកបាទក្រហម ឬ អឌ្ឍច័ន្ទក្រហម ការតម្រូវឱ្យប៉ះប៉ូវសោហ៊ុយខូចខាត និងការកំទេចគ្រឿងឧបករណ៍ដែលប្រើប្រាស់សំរាប់ការផលិតចម្លងបដិរូបនេះ ជាសមត្ថកិច្ចរបស់តុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ១៥ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦ .—**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នស.រកត-០២.០៥-០០៦២

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១០១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាងឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១១៣

## ស្តីពី

## ការទទួលស្គាល់កាកបាទក្រហមកម្ពុជា

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៥៨ ស្តីពីការទទួលស្គាល់សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.—**

ព្រះរាជក្រឹត្យនេះទទួលស្គាល់ កាកបាទក្រហមកម្ពុជា ជាសមាគមស្ម័គ្រចិត្តផ្តល់ជំនួយ និងពីនេះតទៅត្រូវបានទទួលស្គាល់ជា " **កាកបាទក្រហមកម្ពុជា** " ។

មាត្រា ២.—

កាកបាទក្រហមកម្ពុជា បច្ចុប្បន្នជាអ្នកបន្តវេនសមាគមជាតិកាកបាទក្រហមខ្មែរ ដែលបានបង្កើតឡើងតាំងពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៥៥ ក្នុងគោលបំណងផ្តល់ជំនួយសង្គ្រោះ និងធ្វើជាជំនួយការអោយអាជ្ញាធរសាធារណៈ ក្នុងវិស័យមនុស្សធម៌ ។ សមាគមនេះ ត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (ICRC) នៅថ្ងៃទី ០៧ ខែតុលា ឆ្នាំ ១៩៦០ និងត្រូវបានបញ្ចូលជាសមាជិករបស់សហព័ន្ធអន្តរជាតិនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម នៅថ្ងៃទី ០៨ ខែតុលា ឆ្នាំ ១៩៦០ ។

មាត្រា ៣.—

កាកបាទក្រហមកម្ពុជា ត្រូវធ្វើសកម្មភាពដោយត្រឹមត្រូវ ទៅតាមគោលការណ៍គ្រឹះទាំងប្រាំពីររបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ដែលមាន ភាពមនុស្សធម៌, ភាពមិនលំអៀង, អព្យាក្រឹតភាព, ឯករាជ្យភាព, សេវាកម្មស្ម័គ្រចិត្ត, ឯកភាព និង សកលភាព ។

មាត្រា ៤.—

កាកបាទក្រហមកម្ពុជា ត្រូវបានទទួលស្គាល់និងអនុញ្ញាតអោយផ្តល់ការជួយឧបត្ថម្ភចំពោះសេវាកម្មពេទ្យរបស់កងកំលាំងប្រដាប់អាវុធក្នុងពេលមានជំលោះប្រដាប់អាវុធ ដោយផ្អែកលើមូលដ្ឋាននៃ អនុសញ្ញាក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលបានយល់ព្រមដោយ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ១៩៥៨ និងពិធីសារបន្ថែមនាថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ១៩៧៧ ។

មាត្រា ៥.—

កាកបាទក្រហមកម្ពុជា ជានិច្ចកាលត្រូវធ្វើសកម្មភាពត្រឹមត្រូវតាមលក្ខន្តិកៈ វិធាននៃនីតិក្រម និងបទប្បញ្ញត្តិហិរញ្ញវត្ថុ ដែលបានអនុម័តដោយកាកបាទក្រហមកម្ពុជា ។

មាត្រា ៦.—

កាកបាទក្រហមកម្ពុជា ត្រូវបានអនុញ្ញាតអោយប្រើបដិរូបកាកបាទក្រហមនៅលើផ្ទៃស ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួន និងសមស្របទៅតាមអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ពិធីសារបន្ថែមចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ១៩៧៧ និងបទបញ្ជាអំពីការប្រើប្រាស់បដិរូបរបស់សមាគមជាតិ ដែលអនុម័តដោយសន្និសីទអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមលើកទី ២០ និង វិសោធនកម្មជាបន្តបន្ទាប់មកទៀត ។

## ជំពូកទី ២
## គោលដៅ

**មាត្រា ៧ .–**

គោលដៅរបស់កាកបាទក្រហមកម្ពុជា គឺបង្ការនិងបន្ថយទុក្ខលំបាកវេទនា ដោយភាពមិនលំអៀង ដ៏ពិតប្រាកដ ដោយឥតប្រកាន់ពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, ជំនឿ, សាសនា, និន្នាការនយោបាយ, ដើមកំណើតជាតិ, ឋានៈសង្គម, ធនធាន ឬស្ថានភាពឯទៀតឡើយ ។

**មាត្រា ៨ .–**

ដើម្បីបំពេញភារៈកិច្ច ដូចមានចែងក្នុងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ កាកបាទក្រហមកម្ពុជា ត្រូវទទួលយកមុខងាររបស់ខ្លួន ដោយសមស្របទៅតាមលក្ខន្តិកៈ និងបទបញ្ជានៃសន្ធិសញ្ញាអន្តរជាតិ ដែលកម្ពុជាជាភាគីមួយ ហើយនឹងសេចក្តីសំរេចចិត្តរបស់សន្និសីទអន្តរជាតិកាកបាទក្រហម និង អឌ្ឍច័ន្ទ ក្រហម និងឯកសារផ្លូវការផ្សេងៗទៀត របស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ។

## ជំពូកទី ៣
## ទីសាលភាព និង ដែនអនុវត្ត

**មាត្រា ៩ .–**

កាកបាទក្រហមកម្ពុជា ជាសមាគមជាតិកាកបាទក្រហមតែមួយគត់ដែលបំពេញសកម្មភាពមនុស្សធម៌ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

**មាត្រា ១០ .–**

កាកបាទក្រហមកម្ពុជា ជានិច្ចកាលធ្វើសកម្មភាពដោយអនុលោមតាមអនុសញ្ញាក្រុងហ្សឺណែវ និងពិធីសារបន្ថែម ច្បាប់ទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍នៃចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម និងសេចក្តីសំរេចទាំងឡាយដែលអនុម័តដោយ សន្និសីទអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម និងឯកសារផ្លូវការផ្សេងៗទៀតរបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ។

**មាត្រា ១១ .–**

អាជ្ញាធរសាធារណៈ ជានិច្ចកាលត្រូវតែគោរពនូវការផ្សារភ្ជាប់យ៉ាងជិតស្និទរបស់កាកបាទក្រហមកម្ពុជា ទៅនឹងគោលការណ៍គ្រឹះរបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ដូចមានចែងក្នុងសេចក្តីសំរេចលេខ ៥៥ I នៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិ អនុម័តនៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៤៦ ។

មាត្រា ១២ .—

ជាសមាជិករបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម កាកបាទក្រហមកម្ពុជា អាចទទួលយករាល់សកម្មភាពដែលខ្លួនយល់ស្រប ជាមួយនឹងកិច្ចសហប្រតិបត្តិការ និងក្នុងការសំរបសំរួលជាមួយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម សហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ដែលហៅថាសហព័ន្ធ និងសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមដទៃទៀត ។

## ជំពូកទី ៤
## ភារកិច្ច និង តួនាទី

មាត្រា ១៣ .—

កាកបាទក្រហមកម្ពុជា ត្រូវធ្វើតាមភារកិច្ចរបស់ខ្លួនដែលជាសមាសភាគមួយ របស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម និងជាសមាជិកមួយរបស់សហព័ន្ធអន្តរជាតិនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ។

មាត្រា ១៤ .—

កាកបាទក្រហមកម្ពុជា ត្រូវមានរចនាសម្ព័ន្ធអភិបាលកិច្ច និងគ្រប់គ្រងមួយ ដូចមានចែងនិងពណ៌នាដោយលក្ខន្តិកៈរបស់ខ្លួន ។

មាត្រា ១៥ .—

កាកបាទក្រហមកម្ពុជា អាចកែសំរួលលក្ខន្តិកៈ វិធាននៃនីតិក្រម និងបទប្បញ្ញត្តិហិរញ្ញវត្ថុរបស់ខ្លួនគ្រប់ពេលវេលា ដោយធ្វើទៅតាមនីតិវិធី ដែលបានកំណត់ ។

## ជំពូកទី ៥
## ថវិកា និង ធនធាន

មាត្រា ១៦ .—

កាកបាទក្រហមកម្ពុជាគ្រប់គ្រងនិងចាត់ចែងលើធនធាន ថវិកា របស់ខ្លួន ធនធាន និងកំរៃផ្សេងៗទៀត ហើយនិងអំណោយដែលបានមកពីសកម្មភាពនានានិងបេសកកម្មរបស់ខ្លួន ។ លើសពីនេះទៅទៀត កាកបាទក្រហមកម្ពុជា អាចបង្កើតឱ្យមាននិងគ្រប់គ្រងធនធានបំរុង, ធនធានធានារ៉ាប់រង, ធនធានសង្គម ឬធនធានផ្សេងៗទៀតសំរាប់បុគ្គលិក ឬសំរាប់សកម្មភាពណាមួយរបស់ខ្លួន ។

**មាត្រា ១៧ .-**

នៅក្នុងព្រំដែនដែលបានកំណត់ក្នុងទិសដៅ កាកបាទក្រហមកម្ពុជា អាចទទួលយក ធ្វើជាម្ចាស់ ហើយគ្រប់គ្រងទ្រព្យសម្បត្តិ និងសហគ្រាសពាណិជ្ជកម្មផងទាំងពួង ដែលយល់ថាសមស្រប ។ កាកបាទក្រហមកម្ពុជា អាចទទួលយកទ្រព្យសម្បត្តិ ដែលត្រូវបានធ្វើជាអំណោយ ឬត្រូវបានផ្ទេរប្រគល់អោយ សំរាប់ប្រើប្រាស់ ឬសំរាប់ជាប្រយោជន៍របស់កាកបាទក្រហមកម្ពុជា ។

**មាត្រា ១៨ .-**

កាកបាទក្រហមកម្ពុជា អាចទទួលឬបដិសេធវិភាគទាន និងជំនួយគ្រប់ទ្រង់ទ្រាយដែលគ្មានលក្ខខណ្ឌ ពីឯកត្តបុគ្គល ពីអាជ្ញាធរសាធារណៈ និងពីអង្គភាពឯកជន ឬសាធារណៈ សមស្របតាមទិសដៅ និងមុខនាទី របស់ខ្លួន ។

កាកបាទក្រហមកម្ពុជា អាចទទួលធ្វើជាភ្នាក់ងារ ឬជាអ្នកគ្រប់គ្រងមូលនិធិ ឬទ្រព្យសម្បត្តិ ដែលម្ចាស់ទ្រព្យបានផ្តល់ការទុកចិត្តមកលើ ឬបានកំណត់ទុកអោយប្រើប្រាស់ជាពិសេស ក្នុងន័យដែលថា ការប្រើប្រាស់នោះស្ថិតនៅក្នុងវិសាលភាពទូទៅនៃទិសដៅ និងមុខនាទីរបស់ខ្លួន ។

**មាត្រា ១៩ .-**

ចំពោះពន្ធអាករទាំងអស់ ក្នុងនោះមានរាប់បញ្ចូលទាំងអាករបន្ថែមលើតំលៃពន្ធគយ (VAT) និងអាករនានាផង របស់កាកបាទក្រហមកម្ពុជា រួមមានធនធានហិរញ្ញវត្ថុ និងអចលនទ្រព្យ ក៏ដូចជាប្រាក់ចំណូលដែលបានមកពីការធ្វើសកម្មភាពរកចំណូល ជាបន្ទុករបស់រដ្ឋ ។

**មាត្រា ២០ .-**

ជំនួយបរិច្ចាគនានា ដែលឯកត្តបុគ្គល ឬអង្គភាពស្របច្បាប់ណាមួយ បានផ្តល់ជូនកាកបាទក្រហមកម្ពុជា ក្នុងនោះមានទាំងការប្រគល់កេរ្តិ៍មរតកផង ត្រូវបានលើកលែងអោយរួចផុតពីការបង់ពន្ធអាករ ។

**មាត្រា ២១ .-**

អាជ្ញាធរសាធារណៈ ត្រូវចេញថ្លៃចំណាយលើសកម្មភាពណាមួយដែលខ្លួនបំពេញជូនសមាគមជាតិនៅក្នុងវិសាលភាពនៃទិសដៅ និងតួនាទីរបស់កាកបាទក្រហមកម្ពុជា ។ លក្ខខណ្ឌទាំងឡាយសំរាប់ការបំពេញសេវាកម្ម ឬសកម្មភាពទាំងនោះ ត្រូវមានចុះនៅក្នុងកិច្ចព្រមព្រៀងរវាងកាកបាទក្រហមកម្ពុជា និងអាជ្ញាធរសាធារណៈដែលពាក់ព័ន្ធ ។

**មាត្រា ២២ .—**

កាកបាទក្រហមកម្ពុជា ជានិច្ចកាលត្រូវគោរព និងស្ថិតនៅក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិរបស់ខ្លួន ។ កាកបាទក្រហមកម្ពុជា ត្រូវមានវិធានការចាំបាច់ ដើម្បីធានាដល់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងនេះ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ២៣ .—**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៤ .—**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០០២

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រ.ក.០២.០៥.០០១២៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១០០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សរាជី តាំង**

នស/រកត/០៥០២/១១៤

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរសក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

### ក- តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ឯក

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | អ៊ូ | គីមឡឿន | អត្តលេខ ០០០៤៨១ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ទោ | អ៊ុំ | បុត្រ | អត្តលេខ ០០០១៥២ | មេបញ្ជាការរង កងទ័ពជើងគោក |
| ៣-ឧត្តមសេនីយ៍ទោ | ស្វាង | សាឯម | អត្តលេខ ០០០៣៥១ | មេបញ្ជាការរង កងទ័ពជើងគោក |
| ៤-ឧត្តមសេនីយ៍ទោ | ម្សៀន | សារិន | អត្តលេខ ០០០០៦៤ | មេបញ្ជាការរង កងទ័ពជើងគោក |

## ខ- តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី អ៊ិន ចាន់ថា អត្តលេខ ០០០៨៧០ អនុរដ្ឋលេខាធិការក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ត្រី ហ៊ុយ កែវ អត្តលេខ ០០០១៦៨ នាយក មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា អគ្គបញ្ជាការដ្ឋាន

## គ- តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក ឈួន សារឿន អត្តលេខ ០០០៩៣៨ នាយករង នាយកដ្ឋានបុគ្គលិក

២-វរសេនីយ៍ឯក មាស លី អត្តលេខ ០០០៩២៨ នាយករង នាយកដ្ឋានបុគ្គលិក

៣-វរសេនីយ៍ឯក ចាន់ សារ៉ន អត្តលេខ ០០០៩២៧ នាយករងខុទ្ទកាល័យក្រសួងការពារជាតិ

៤-វរសេនីយ៍ឯក ទួច តិរម្យ អត្តលេខ ០០០៩២៦ នាយករងនាយកដ្ឋាននយោបាយផែនការ

៥-វរសេនីយ៍ឯក ទៀត ឡៃហ៊ាង អត្តលេខ ០០១៨១៨ នាយករង នាយកដ្ឋាននីតិកម្ម

៦-វរសេនីយ៍ឯក ជា ចាសនា អត្តលេខ ០០៣២១០ នាយករង នាយកដ្ឋាននីតិកម្ម

៧-វរសេនីយ៍ឯក នួន សំបូរ អត្តលេខ ០០០៩៥៦ នាយករង នាយកដ្ឋានភូមិសាស្ត្រ

៨-វរសេនីយ៍ឯក យិន សុខា អត្តលេខ ០០១៦២០ នាយករង វិទ្យាស្ថានយោធាកម្ពុជា

៩-វរសេនីយ៍ឯក អៀង ផលលាភ អត្តលេខ ០០០៩៦៥ នាយករង នាយកដ្ឋានហិរញ្ញវត្ថុ

១០-វរសេនីយ៍ឯក សុខ ចណ្ណារ៉ា អត្តលេខ ០០០៩៦៧ នាយករង នាយកដ្ឋានហិរញ្ញវត្ថុ និងជានាយកការិយាល័យផែនការ អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ

១១-វរសេនីយ៍ឯក អោម ចិចិត្រ អត្តលេខ ០០០៩៦៨ នាយករង នាយកដ្ឋានបច្ចេកទេស និងជានាយកការិយាល័យផែនការ អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

១២-វរសេនីយ៍ឯក ស៊ុំ ចាំចាន់នារ៉ុង អត្តលេខ ០០០៩៦៨ នាយករង នាយកដ្ឋានពត៌មាន និងជានាយកការិយាល័យផែនការ អគ្គនាយកដ្ឋានយោធសេវា

១៣-វរសេនីយ៍ឯក ម៉ូ ផាន់សារី អត្តលេខ ០០០៦១៣ នាយករង នាយកដ្ឋានវិស្វកម្ម

១៤-វរសេនីយ៍ឯក ស៊ឹម សុភាព អត្តលេខ ០០០៦០៥ នាយករង នាយកដ្ឋានអប់រំ

១៥-វរសេនីយ៍ឯក នាង ផែន អត្តលេខ ០០០៦០២ នាយករង នាយកដ្ឋានអប់រំ

១៦-វរសេនីយ៍ឯក ព្រហ្ម ឌីត អត្តលេខ ០០១៦៤១ នាយករងនាយកដ្ឋានទាក់ទងអន្តរជាតិ

១៧-វរសេនីយ៍ឯក អ៊ុង សារិទ្ធ អត្តលេខ ០០១១០០ នាយករងទីចាត់ការចលនូប្បត្ថម្ភ អគ្គបញ្ជាការដ្ឋាន

១៨-វរសេនីយ៍ឯក សួន សុចណ្ណ អត្តលេខ ០០០៨៣៤ ទីប្រឹក្សា អគ្គមេបញ្ជាការ

១៩-វរសេនីយ៍ឯក ជា សុខណ្ណធម្ម អត្តលេខ ០០០៨៦២ នាយករង នាយកដ្ឋានស្រាវជ្រាវ
ចារកិច្ច អគ្គបញ្ជាការដ្ឋាន

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣ករ.០២.០៥-០០១២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ ២០០២

លេខ: ១០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សរ ឌី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ៣៤.អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតវិទ្យាស្ថានគ្រប់គ្រងនិងពត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦,០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញលិខិតស្នើសុំរបស់ លោក ឃី ងី ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០២
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រេ ច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើត គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានគ្រប់គ្រង និង**

ពត៌មានវិទ្យា (Institute of Management and Informatics) ហៅកាត់ជាភាសាខ្មែរ "វគព" និងហៅកាត់ជាភាសាអង់គ្លេស "IMI" ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំង នៅផ្លូវ អូរ ០១ សង្កាត់ ០៤ ខណ្ឌ មិត្តភាព ក្រុងព្រះសីហនុ ។

**មាត្រា ២ :** វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សា យ៉ាងតិច ៤ ឆ្នាំ ។

**មាត្រា ៣ :** វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មាន :

- មហាវិទ្យាល័យ គ្រប់គ្រងនិងទេសចរណ៍
- មហាវិទ្យាល័យ សេដ្ឋកិច្ចនិងពត៌មានវិទ្យា

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេសជំនាញ ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍ របស់វិទ្យាស្ថាន និងមាន ក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ សំរាប់ពិនិត្យលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** នាយកវិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មានភារកិច្ច :

- ជ្រើសរើសនិស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវ ការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា និង បានទទួលជោគជ័យក្នុងការប្រលង បញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយ ដោយវិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និង អនុវត្ត តាមគោលការណ៍ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មានភារកិច្ចរៀង ៗ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ៨ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងព្រះសីហនុ

  " ដើម្បីមុខការ "
- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការបង្វែរការគ្រប់គ្រងឥណទានថវិកា

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៦៩ , ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នរ/រកម/០១.៩៩/០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

៤

## សម្រេច

**មាត្រា១:** ត្រូវបានបង្វែរការគ្រប់គ្រង «មូលនិធិសំរាប់ជួសជុល ថែទាំផ្លូវថ្នល់» មកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ដោយមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសេនាធិការ ។

**មាត្រា២:** មូលនិធិនេះនឹងត្រូវប្រើសំរាប់ជាគុណប្រយោជន៍នៃបេសកកម្មជួសជុលជាប្រចាំ និង ជួសជុលថែទាំខួបនៃផ្លូវជាតិ ផ្លូវខេត្ត និង ផ្លូវនានា ។

**មាត្រា៣:** យន្តការ និង បរិបថនៃការគ្រប់គ្រង និង ត្រួតពិនិត្យហិរញ្ញវត្ថុលើឥណទាន « បូលនិធិសំរាប់ជួសជុល ថែទាំផ្លូវថ្នល់ » នេះនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកព្រឹទ្ធាចារ្យ **ហ៊ុន នាង** ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលផ្សេងៗក្នុងវិស័យព្រះពុទ្ធសាសនា តាមបណ្តាខេត្តនានាទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងនោះរួមមាន: ព្រះវិហារ សាលាធម្មសភា សាលាឆទាន បណ្ណាល័យ កុដិ អណ្តូងទឹក ម៉ាស៊ីនភ្លើង និង មេក្រូ ផ្លូវថ្នល់ជាដើម សរុបជាទឹកប្រាក់ចំនួន ២៦១.៦០០ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈកម្មាការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤១៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា ដូចជា : បណ្ណាល័យ ជួសជុលសាលាធម្មសភា កុដិ ធ្វើផ្លូវអំពីបេតុងអាងទឹក ក្នុងបរិវេណវត្តបុទុមវត្តី សរុបទឹកប្រាក់ចំនួន ៩០.៦០០ USD ដូចមានរាយព្រះនាម និងនាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-សម្តេចព្រះពោធិវង្ស | **នន្ទ** | **ង៉ែត** | ចៅអធិការវត្តបុទុមវត្តី |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ខ្វាន់** | **ស៊ាម** | មេបញ្ជាការបញ្ជាការដ្ឋានវិស្វកម្ម |
| ៣-វរសេនីយ៍ឯក | **មាស** | **ឈុនហេង** | មេបញ្ជាការរងអន្តរាគមន៍ស្ពានថ្នល់ទី១បញ្ជាការដ្ឋានវិស្វកម្ម |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង គណៈកម្មាការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧១៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ០៧ រូប ដែលបានចូលរួមកសាងព្រះវិហារ វត្តប្រាំង្គមណីជោតនារាម ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ដូចមាននាម និង ទឹកប្រាក់ខាងក្រោម ÷

**ក_មេដាយមាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **ហ៊ិន** | **ម៉ុន** | ចៅអធិការវត្ត | បច្ច័យ ១១.០០០ USD |
| ២-លោកយាយ | **គឹម** | **ទ៉ាត** | | ថវិកា ១៣.០០០ USD |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **យឹម** | **ហៃ** | ថវិកា ៨.៥០០ USD |
| ២-លោក | **គិត** | **សុវណ្ណារី** | ថវិកា ៦.០០០ USD |
| ៣-លោក | **តុខ** | **ហ៊ី** | ថវិកា ៦.៥០០ USD |
| ៤-លោក | **វ័ត្ន** | **សារឿន** | ថវិកា ៥.៥០០ USD |
| ៥-លោកស្រី | **លៀខ** | **ជា** | ថវិកា ៥.៥០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២១៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា១** : ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-ឧត្តមសេនីយ៍ទោ **ថោង នៅ** អត្តលេខ ០០០០៤៧ បច្ចុប្បន្នជា ទីប្រឹក្សាក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ត្រី **ឃិន សារ៉ាន់** អត្តលេខ ០០១៤៤០ មេបញ្ជាការអង្គរក្សសម្តេចប្រធានព្រឹទ្ធសភា បច្ចុប្បន្នជា មេបញ្ជាការរងកងទ័ពជើងទឹក

៣-ឧត្តមសេនីយ៍ត្រី **ហ៊ុយ តែង** អត្តលេខ ០០០១៦៨ នាយកស្តីទី មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា បច្ចុប្បន្នជា នាយកមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា

៤-វរសេនីយ៍ឯក **ឆ្មុំង សារិទ្ធ** អត្តលេខ ០០១១០០ មេបញ្ជាការរងអង្គរក្ស បច្ចុប្បន្នជា នាយករងទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន

៥-វរសេនីយ៍ឯក សួខ សុទណ្ណ អត្តលេខ ០០០៨៣៤ មេបញ្ជាការរងអង្គរក្ស បច្ចុប្បន្នជា ទីប្រឹក្សា អគ្គមេបញ្ជាការ

៦-វរសេនីយ៍ឯក ជា សុទណ្ណធូម អត្តលេខ ០០០៨៦២ នាយសេនាធិការរង យោធភូមិភាគពិសេស បច្ចុប្បន្នជា នាយករង នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ ✓

6

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២១៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
